Cambodian Women's Crisis Center

របាយការណ៍ប្រចាំឆ្នាំ ២០២០

សមាជិកក្រុមសន្សំដែលបានរៀនជំនាញកាត់ដេរពីគម្រោង CWCC ហើយបច្ចុប្បន្នជាអ្នកលក់
សំលៀកបំពាក់សហគមន៍នៅ ភូមិទួលធ្នង់ ឃុំគោល ស្រុកប្រាសាទសបូរ ខេត្តកំពង់ធំ

សេចក្តីផ្តើម

បើទោះជាមានយន្តការជាតិនិងយន្តការទាំងឡាយ ត្រូវបានដាក់ឲ្យអនុវត្តន៍ ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជាយ៉ាងណាក៏ដោយ យើងមិនអាចនិយាយបានថា សមភាពយេនឌ័រនៅកម្ពុជាសម្រេចបានទាំងស្រុងនោះទេ។ ស្ត្រីភាគច្រើនដែលរស់នៅទីជនបទដាច់ស្រយាលពុំទទួលបាននូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួននោះទេ ដោយស្ត្រីនិងក្មេងស្រីទាំងនោះមិនទទួលបាននូវភាពស្មើគ្នាក្នុងការទទួល សេវាថែទាំសុខភាព ការអប់រំ អាជីពការងារ និងការចូលរួមផ្តែកនយោបាយ។ មួយវិញទៀត អំពើហិង្សាក៏បាននិងកំពុងកើតមានឡើងជារៀងរាល់ថ្ងៃ ដែលបង្ករឲ្យមានអស្ថេរភាពក្នុងគ្រួសារ ភាពក្រីក្រ និងការធ្លាក់ចុះនូវធនធានមនុស្ស។ កត្តាទាំងនេះបានជះឥទ្ធិពលអាក្រក់មកលើប្រជាជនជាច្រើនជាពិសេសគឺស្ត្រី ដែលធ្វើឲ្យពួកគេពុំអាចប្រើប្រាស់សិទ្ធិមនុស្សជាសកលរបស់ខ្លួនបាន។

អង្គការ CWCC បាននឹងកំពុងធ្វើការយ៉ាងជិតស្និត ជាមួយម្ចាស់ជំនួយដោយទទួលបានការគាំទ្រ និង ការគិតគូរអំពីបំលាស់ប្តូរនិន្នាការនៅក្នុងការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ ។

អង្គការ CWCC ផ្តោតការយកចិត្តទុកដាក់ក្នុងការធ្វើអន្តរាគមន៍ និងផ្តល់សេវា ដើម្បីកាត់បន្ថយអំពើរហិង្សា និងពង្រឹងសិទ្ធអំណាចដល់ស្ត្រី ជាពិសេសពាក់ព័ន្ធនឹងបញ្ហាអំពើរហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្តវៈ ការរំលោភបំពានផ្លូវភេទ និងការជួញដូរផ្លូវភេទ ការជួញដូរស្ត្រីនិងកុមារ និងការទទួលបានភាពស្មើគ្នារបស់ក្មេងស្ត្រីក្នុងវិស័យអប់រំ ។

វិធីសាស្ត្ររបស់អង្គការ



តំបន់គោលដៅរបស់អង្គការ

- រាជធានីភ្នំពេញ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តសៀមរាប៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តបន្ទាយមានជ័យ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តកំពង់ធំ៖ ការិយាល័យប្រចាំតំបន់

យុទ្ធសាស្ត្ររបស់អង្គការ

ទស្សនវិស័យ

ស្ត្រី និងកុមារី រស់នៅដោយសន្តិភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ហើយរីករាយនឹងសិទ្ធិមនុស្ស ជាសកលរបស់ខ្លួន។

បេសកម្ម

ពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីឲ្យទាមទារសិទ្ធិជាសកលរបស់ខ្លួន ដើម្បីទទួលបាននូវ សុវត្ថិភាពផ្ទាល់ខ្លួន និងចូលរួមដោយស្មើភាពគ្នាក្នុងការងារសហគមន៍ សង្គមស៊ីវិល ការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងចូលរួមក្នុងសកម្មភាពនយោបាយ សង្គម និងវប្បធម៌។

ទិសដៅរួម

ចូលរួមពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីដែលរងគ្រោះ និងងាយរងគ្រោះ តាមរយៈការទប់ស្កាត់ ការការពារ និងការតស៊ូមតិ ដើម្បីលើកកម្ពស់ឲ្យមានសង្គមមួយដែលមាន សន្តិភាព សមភាពយេនឌ័រ និងក្តីមេតា ករុណា។

តម្លៃស្នូល

សេចក្តីថ្លៃថ្នូរ៖ មនុស្សគ្រប់រូប ដោយមិនគិតពីហានៈ ភេទ អសមត្ថភាព និងភាពខុសប្លែកដទៃទៀត គឺត្រូវរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

ភាពយុត្តិធម៌៖ មនុស្សគ្រប់រូប គួរតែរីករាយ និងទទួលបាននូវសិទ្ធិស្មើគ្នា នៅក្នុងការចូលរួមនៅក្នុងកិច្ចការនយោបាយ និងការអនុវត្ត ដែលអាចទទួលបាននូវការបែងចែកអំណាច ធនធាន និងឱកាសស្មើៗគ្នា។

គណនេយ្យភាព៖ ធនធាន និងការទទួលខុសត្រូវ សម្រាប់ធ្វើការសម្រេចចិត្ត ត្រូវបានប្រើប្រាស់ ជាមធ្យោបាយមួយ សម្រាប់ធ្វើឲ្យមានតម្លាភាព និងអាចឆ្លើយតបទៅនឹងម្ចាស់ជំនួយ ដែលស្រប តាម ធម្មនុញ្ញភាព ព្រមទាំងបំពេញតម្រូវការសហគមន៍។

កម្មវិធីរបស់អង្គការ

គោលដៅរួមរបស់អង្គការនឹងត្រូវបានសម្រេចឡើងតាមរយៈគោលដៅយុទ្ធសាស្ត្រចំនួនបួន៖

គោលបំណងយុទ្ធសាស្ត្រទី១: កម្មវិធីទប់ស្កាត់

គោលបំណងយុទ្ធសាស្ត្រទី២: កម្មវិធីការពារ

គោលបំណងយុទ្ធសាស្ត្រទី៣: កម្មវិធីតស៊ូមតិ

គោលបំណងយុទ្ធសាស្ត្រទី៤: ការអភិវឌ្ឍន៍អង្គការ

១. កម្មវិធីទប់ស្កាត់

១.១ គម្រោងរៀបចំសហគមន៍

ការអប់រំ នឹងពង្រឹងសិទ្ធអំណាចដល់ប្រជាពលរដ្ឋក្នុងសហគមន៍ មន្ត្រីមានកាតព្វកិច្ច អ្នកដឹកនាំសហគមន៍ និងអាណាព្យាបាល ដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគាត់ទាក់ទងនឹងសិទ្ធស្ត្រីនិងកុមារ គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រផ្សេងៗទៀតរបស់ អង្គការ CWCC ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។ គម្រោងរៀបចំសហគមន៍(CO) បានផ្តល់ការកសាងសមត្ថភាពដល់មន្ត្រីមានកាតព្វកិច្ច ដែលរួមមាន អ្នកដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីប៉ូលីសអំពីសិទ្ធស្ត្រី សិទ្ធរបស់ជនពិការ អំពើហិង្សាទាក់ទងយេនឌ័រ(GBV) ច្បាប់អំពើហឹង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរ និង លើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

ក្នុងឆ្នាំ ២០២០ គម្រោងបានធ្វើការដោយផ្ទាល់ជាមួយក្រុមគាំទ្រស្ត្រីដែលមានសមាជិកចំនួន១៨០នាក់ ក្រុមយុវជនដែលមានសមាជិក១៨០នាក់ (ស្ត្រី១១៦នាក់) និង បណ្តាញចម្រុះថ្នាក់ស្រុកចំនួន ២៩២នាក់ (ស្ត្រី១១០នាក់) ។ ក្រុមទាំងអស់បានដើរតួរនាទីជាភ្នាក់ងារសម្រាប់ធ្វើអោយមានការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេរៀងៗខ្លួន តាមរយៈការលើកកំពស់ការយល់ដឹងទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ប្រមាណជា ៧,៥០០នាក់ ដែលក្នុងនោះ៦៥%ជាស្ត្រី ។

១.២ គម្រោងគ្រប់គ្រងកំហឹងបុរស

គម្រោងគ្រប់គ្រងកំហឹងបុរស (AMM) របស់អង្គការ CWCC បានធ្វើការស្វែងរកដំណោះស្រាយចំពោះបញ្ហាអំពើហិង្សាក្នុងគ្រួសារតាមរយៈការធ្វើការជាមួយមន្ត្រីមានកាតព្វកិច្ច និងបុរសដែលមានឥរិយាបថហិង្សា ។ គម្រោងមិនត្រឹមតែផ្តល់ការការពារ និងផ្តល់សិទ្ធអំណាចដល់ជនរងគ្រោះដោយអំពើរហឹង្សាក្នុងគ្រួសារតែប៉ុណ្ណោះទេ ថែមទាំងលើកកំពស់ការយល់ដឹងអំពីច្បាប់អំពើហិង្សាក្នុងគ្រួសាររបស់ប្រទេសកម្ពុជាទៅដល់ស្វាមី និងពង្រឹងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តន៍ច្បាប់ទាំងនេះផងដែរ ។ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានផ្តល់វគ្គបណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ដោយអហិង្សា ដោយឡែកវគ្គបណ្តុះបណ្តាលទាំងនោះនិយាយអំពីអំពើហិង្សាទូរទៅ ។ សម្រាប់គម្រោងគ្រប់គ្រងកំហឹងបុរស (AMM) របស់អង្គការ CWCC គឺជាគម្រោងតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលធ្វើការដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារតាមរយៈការដោះស្រាយដោយផ្ទាល់នូវឫសគល់របស់បញ្ហា ។ វិធីសាស្ត្រនេះមិនត្រឹមតែផ្តល់ការការពារដល់ជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងធានាបាននូវការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារប្រកបដោយនិរន្តរភាពផងដែរ ។

គម្រោងបានធ្វើការដោយផ្ទាល់ជាមួយបុរសដែលជាមិត្តអប់រំមិត្តចំនួន ១៤០នាក់ ក្នុងការផ្តល់ការប្រឹក្សា ទៅដល់បុរសដែលប្រឈមនិងការប្រព្រឹត្តអំពើហិង្សាចំនួន ២០៧នាក់ និងលើក

កម្ពស់ការយល់ដឹងទៅដល់ពលរដ្ឋក្នុងសហគមន៍ចំនួន ៥៣២នាក់ (ស្ត្រី៤១២នាក់) ក្នុងខេត្តសៀមរាប ។

គម្រោងក៏បានធ្វើការសម្របសម្រួលអាណាព្យាបាលដើម្បីបង្កើតជាក្រុមឪពុកម្តាយគំរូ និងផ្តល់អោយពួកគាត់នូវវគ្គបណ្តុះបណ្តាលនានាអំពីឪពុកម្តាយគំរូ ដែលមានដូចជា ភាពជាឪពុកម្តាយ តួរនាទីនិងការទទួលខុសត្រូវ ការប្រើប្រាស់ពេលវេលាសម្រាប់កូន គុណតម្លៃវិន័យជាវិជ្ជមាន ការធ្វើទំនាក់ទំនងល្អក្នុងគ្រួសារ សន្តិភាពក្នុងគ្រួសារ ការការពារកុមារ និងការរៀបចំថវិការគ្រួសារ ។ ស្របពេលនៃការផ្តល់វគ្គបណ្តុះបណ្តាលនេះ គម្រោងក៏បានកសាងនូវភាពជឿជាក់ដល់ក្រុម និងបានជម្រុញទឹកចិត្តអោយពួកគាត់ក្លាយជាឪពុកម្តាយល្អដែលគោរពទៅតាមសិទ្ធកុមារ ។ បច្ចុប្បន្នមានក្រុមឪពុកម្តាយគំរូចំនួន១០ដែលមានសមាជិក ២៣៥នាក់ ។ ដោយមានការកើនឡើងនូវការយល់ដឹងអំពីភាពជាឪពុកម្តាយគំរូ ក្រុមឪពុកម្តាយគំរូបានលើកកំពស់ការយល់ដឹងទៅដល់ពលរដ្ឋក្នុងសហគមន៍ចំនួន ១៨៣នាក់ (ស្ត្រី១៦៩ នាក់) ។ ក្រុមគាំទ្រកុមារចំនួន ៦ក្រុម ដែលមានសមាជិក១៤៨នាក់(កុមារី៨៥នាក់) ក៏ត្រូវបានបង្កើតឡើងស្របពេលជាមួយគ្នានឹងការបង្កើតក្រុមឪពុកម្តាយគំរូផងដែរ ។ ក្រុមគាំទ្រកុមារទាំង៦ក្រុមនេះបានចែករំលែកចំណេះដឹងដែលពួកគេទទួលបានពីការកសាងសម្ថភាពដែលគម្រោងបានផ្តល់អោយកាន់មិត្តភក្រតាមរយៈការផ្តល់ប្រឹក្សាទៅដល់មិត្តភក្ររបស់ពួកគេ ។

១.៣ គម្រោងលើកកម្ពស់ការអប់រំរបស់ក្មេងស្រី

គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់កុមារីងាយរងគ្រោះ ដែលក្នុងនោះរួមមានកុមារីមកពីគ្រួសារក្រីក្រ កុមារីដែលមានអំពើហិង្សាក្នុងគ្រួសារ និងកុមារីដែលប្រឈមមុខនឹងការបោះបង់ចោលការសិក្សារ នៅក្នុងតំបន់គោលដៅនៃខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តបន្ទាយមានជ័យ ។ ក្នុងឆ្នាំ២០២០ គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់ក្មេងស្រីចំនួន១៦២នាក់ចាប់ពីកំរិតអនុវិទ្យាល័យ ដល់កំរិតវិទ្យាល័យ (ក្មេងស្រី១០០នាក់ក្នុងខេត្តសៀមរាប ៦២នាក់ក្នុងរាជធានីភ្នំពេញ និង ២៥នាក់ក្នុងខេត្តបន្ទាយមានជ័យ) ។ គម្រោងបានធ្វើការសហការណ៍ជាមួយក្រុមការងារអប់រំថ្នាក់មូលដ្ឋាន និង ក្រុមសម្របសម្រួលថ្នាក់ស្រុកក្នុងការជ្រើសរើសក្មេងស្រីអាហារូបករណ៍ និងផ្តល់កញ្ចាប់អាហារូបករណ៍ដើម្បីគាំទ្រការសិក្សារបស់ពួកគេ ។ កញ្ចប់អាហារូបករណ៍ដែលគម្រោងបានផ្តល់ជូនរួមមាន សម្ភារៈសិក្សារ ឯកសណ្ឋានសិស្ស កង់ ប្រាក់ឧបត្ថមប្រចាំខែ ប្រាក់សម្រាប់រៀនគួរក្រៅម៉ោង វគ្គបណ្តុះបណ្តាលកំព្យូទ័រ និងភាសារអង់គ្លេស។ ការផ្តល់ជូនទាំងនេះបានជួយសម្រួលអោយក្មេងស្រីបន្តការសិក្សា និងទៅរៀនបានទៀងទាត់ ។ ពិសេសជាងនេះទៅទៀត គម្រោងបានរៀបចំកន្លែងស្នាក់នៅចំនួន៥កន្លែងក្នុងខេត្តសៀមរាប សម្រាប់សិស្សស្រីអាហារូបករណ៍ដែលរស់នៅឆ្ងាយជាង៧គីឡូម៉ែត្រពីសាលារៀន។

ក្មេងស្រីដែលមកពីគ្រួសារក្រីក្រ អាចមានលទ្ធភាពក្នុងការរៀនសូត្រ និងបន្តរការសិក្សារបស់ខ្លួនទៅកាន់វគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ តាមរយៈកញ្ចប់អាហារូបករណ៍ និងបណ្តាញរបស់គម្រោងជាមួយសាលាជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈនានា ។

១.៤ គម្រោងពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

កម្មវិធីពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រីមានគោលបំណង ផ្តល់សិទ្ធអំណាចដល់ស្ត្រី និងក្មេងស្រីដែលរស់នៅក្នុងតំបន់គោលដៅ ដើម្បីអោយពួកគាត់មានជីវភាពរស់នៅល្អប្រសើរ ជាមួយនឹងបណ្តាញសង្គមដ៏រឹងមាំមួយដើម្បីជួយអោយពួកគាត់យកឈ្នះលើបញ្ហាហិរញ្ញវត្ថុ និងកាត់បន្ថយភាពងាយរងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សា ។ ក្នុងឆ្នាំ២០២០ គម្រោងបានធ្វើការជាមួយក្រុមសន្សំ៥៧ក្រុម ដែលក្នុងនោះមាន២៥ក្រុមក្នុងខេត្តសៀមរាប ១២ក្រុមក្នុងខេត្តកំពង់ធំ។ ក្រុមទាំងអស់មានសមាជិកសរុបចំនួន ១០៨៧នាក់ (ស្ត្រី៨៧៥នាក់)។ ក្រៅពីនេះ គម្រោងក៏បានធ្វើការគាំទ្រដល់ក្រុមស្ត្រីធ្វើអាជីវកម្មចំនួន៣៣ក្រុម និងស្ត្រីធ្វើអាជីវកម្មចំនួន ៥៥នាក់ ក្នុងគោលបំណងជួយអោយពួកគាត់មានជំនាញ និងអាចរកប្រាក់ ចំណូលសម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ ។

បន្ថែមលើនេះទៅទៀត ក្រុមសហព័ន្ធចំនួន៣ក្នុងខេត្តសៀមរាប (២ក្រុមនៅស្រុកក្រឡាញ់ និង១ក្រុមនៅស្រុកសៀមរាប) និងក្រុមសហព័ន្ធ៣ក្រុមផ្សេងទៀតក្នុងខេត្តកំពង់ធំ (១ ក្រុមស្រុកប្រាសាទសំបូរ ១នៅស្រុកសន្ទុក និង១នៅស្រុកប្រាសាទបាល័ង្គ) ដែលបច្ចុប្បន្នកំពុង ដំណើរការយ៉ាងល្អ ។ ក្រុមសហព័ន្ធមានកាតព្វកិច្ចក្នុងការជួយសម្របសម្រួលក្រុមសន្សំអោយមានដំណើរការទៅមុខល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព។ ក្រុមសហព័ន្ធទាំងអស់ត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន ហើយបានរៀបចំរបាយ ការណ៍ទៅដល់អាជ្ញាធរមូលដ្ឋានជាប្រចាំ ។

១.៥ គម្រោងចំណាកស្រុកសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស

គម្រោងបានអនុវត្តន៍នៅតំបន់គោលដៅ ក្នុងខេត្តបន្ទាយមានជ័យ កំពង់ធំ សៀមរាប និងរាជធានីភ្នំពេញ ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងស្តីពីការធ្វើចំណាកស្រុកមានសុវត្ថិភាព ការការពារសិទ្ធិមនុស្ស ដែលរួមមានសិទ្ធរបស់ពលករចំណាកស្រុក (រួមបញ្ចូលទាំងស្ត្រី និងកុមារ) និងបង្ការភាពងាយរងគ្រោះនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស។ តាមរយៈគម្រោងក៏បានបង្កើតក្រុមជួយខ្លួនឯងចំនួន២៤ក្រុម មានសមាជិកសរុបចំនួន៨៨០នាក់ (ស្ត្រី ៧០៤នាក់) ដែលពួកគេទាំងអស់សុទ្ធសឹងជា ឪពុកម្តាយរបស់ពលករចំណាកស្រុក អតីតពលករចំណាកស្រុក និង ប្រជាជនមូលដ្ឋាន ។

ក្នុងឆ្នាំ២០២០ គម្រោងបានធ្វើការផ្សព្វផ្សាយចំណេះដឹងស្តីពីការធ្វើចំណាកស្រុកមានសុវត្ថិភាព និងទប់ស្កាត់ការជួយដូរមនុស្សទៅកាន់ប្រជាជនក្នុងសហគមន៍សរុបចំនួន ៣២៦៨នាក់ (ស្ត្រី៨០%)។ ដោយឡែកយុទ្ធនាការ១២ធ្នូប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមិនបានប្រារព្ធឡើងទេដោយសារការីករាលដាលនៃជំងឺ Covid-19។

២. កម្មវិធីការពារ

២.១ គម្រោងលើកកម្ពស់បណ្តាញសហគមន៍ ដើម្បីការពារស្ត្រីនិងកុមារពីរាល់ទម្រង់នៃអំពើហិង្សា

គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកបណ្តាញចម្រុះថ្នាក់ស្រុក ដែលពូកគាត់សុទ្ធសឹងតែជាមន្ត្រីមកពីការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច គណៈកម្មាការទទួលបន្ទុកស្ត្រីនិងកុមារ បុគ្គលិកមណ្ឌលសុខភាព ប៉ូលីស និង បុគ្គលដែលជាធនធានសហគមន៍ដែលមានស្រាប់ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកំពង់ធំ ។ ជាលទ្ធផល ក្រុមបណ្តាញចម្រុះថ្នាក់ស្រុក បានជួយដោះស្រាយវិវាទចំនួន៤៩២ករណី ក្នុងចំណោមករណីទាំងនេះមាន ៤៧៧ករណីជាករណីអំពើរហិង្សាក្នុងគ្រួសារ ១១ករណីរំលោភបំពានផ្លូវភេទនិង ៤ករណីជួញដូរមនុស្ស។ តាមរយៈការអន្តរាគមន៍នេះ ស្ត្រី និងកុមារដែលជាជនរងគ្រោះនៃអំពើហិង្សាបានទទួលសេវាដែលសមស្រប និងឆ្លើយតបទៅតាមតម្រូវការរបស់ពួកគេ ។

២.២ គម្រោងជំនួយផ្នែកច្បាប់

ក្នុងឆ្នាំ ២០២០ មានករណីអំពើហិង្សាទាក់ទងយេនឌ័រចំនួន ៥៨៤ករណីដែលមានសាច់ញាតិចំនួន៨២នាក់ បានទទួលសេវាកម្មគ្រប់ជ្រុងជ្រោយពីការិយាល័យអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និង ខេត្តកំពង់ធំ ។ ក្នុងចំណោមករណីទាំងនោះ មាន៣៧០ជាករណីអំពើហិង្សាក្នុងគ្រួសារ ១០៦ជាករណីរំលោភបំពានផ្លូវភេទ និង ៨ជាករណីជួញដូរមនុស្ស ។

ទិន្នន័យករណីអំពើហិង្សាទាក់ទងយេនឌ័រ ឆ្នាំ ២០២០

ករណី	ភ.ព	ប.ជ	ស.រ	ក.ធ	សរុប
អំពើហិង្សាក្នុងគ្រួសារ	១១៥	៥៨	១០៧	៩០	**៣៧០**
ការរំលោភបំពានផ្លូវភេទ	៣២	៧	៤៥	២២	**១០៦**
ការជួញដូរមនុស្ស	៤	៣	០	១	**៨**
សរុប	**១៥១**	**៦៨**	**១៥២**	**១១៣**	**៥៨៤**

ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប

សម្រាប់ដំណើរការនៃការទទួលករណី ៣៦%នៃជនរងគ្រោះមកទទួលសេវាពីអង្គការ CWCC ដោយខ្លួនឯង និង៥០%ត្រូវបានបញ្ជូនមកកាន់អង្គការ ។ ១៤%ត្រូវបានជួយសង្គ្រោះដោយមានការចូលរួមពីអង្គការ CWCC ។

ភាគរយនៃចំនួនអតិថិជនដែលមកទទួលសេវាពីអង្គការCWCC ឆ្នាំ២០២០



គម្រោងជំនួយផ្នែកច្បាប់បានផ្តល់ការប្រឹក្សាផ្នែកច្បាប់ និងគាំទ្រជនរងគ្រោះដែលសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅកាន់តុលាការ តាមរយៈការជួយបំពេញឯកសារពត៌មានពាក្យបណ្តឹង និងស្វែងរកភស្តុតាងនានា ដូចជាការសម្របសម្រួលក្នុងការធ្វើកោសល្យវិច្ច័យនៅមន្ទីពេទ្យ ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ដែលមកស្វែងរកជំនួយពីអង្គការCWCCក្នុងឆ្នាំ២០២០ មានជនរងគ្រោះ២៦៩នាក់ស្នើរសុំជំនួយផ្នែកច្បាប់ ដែលករណីរបស់ពួកគេត្រូវបានបញ្ជូនទៅកាន់តុលាការរាជធានី និងខេត្ត ។ ជាលទ្ធផល មាន១២០ករណីត្រូវបានបញ្ចប់តាមដំណើរការផ្លូវច្បាប់របស់តុលាការ ។ ក្នុងចំណោមទាំង១២០ ករណីនោះ មាន៨១ករណីដែលជនប្រព្រឹត្តបទល្មើសត្រូវកាត់ទោសអោយជាប់ពន្ធនាគារ (៦៨ករណីជាករណីរំលោភបំពានផ្លូវភេទ និង១៣ករណីជាករណីអំពើហិង្សាក្នុងគ្រួសារ) ។

ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលដាក់ពាក្យបណ្តឹងទៅតុលាការ ឆ្នាំ២០២០

ករណី	ករណីក្រោមអាយុ១៨ឆ្នាំ					ករណីលើអាយុ១៨ឆ្នាំ					សរុបរួម
	ភ.ព	ប.ជ	ស.រ	ក.ធ	**សរុប**	ភ.ព	ប.ជ	ស.រ	ក.ធ	**សរុប**	
អំពើហិង្សាក្នុងគ្រួសារ	០	០	០	០	**០**	៧៦	១	៧៤	៤០	**១៩១**	**១៩១**
រំលោភបំពានផ្លូវភេទ	២៦	០	២៩	១៣	**៦៨**	៣	០	២	៥	**១០**	**៧៨**
ការជួញដូរមនុស្ស	០	០	០	០	**០**	០	០	០	០	**០**	**០**
សរុប	**២៦**	**១៥**	**២៩**	**១៣**	**៦៨**	**៧៩**	**១**	**៧៦**	**៤៥**	**២០១**	**២៦៩**

ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប

ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលបានជំនុំជម្រះ ឆ្នាំ២០២០

ករណី	ភ.ព	ប.ជ	ស.រ	ក.ធ	សរុប
អំពើហិង្សាក្នុងគ្រួសារ	២០	១	២៤	៧	៥២

រំលោភបំពានផ្លូវភេទ	៣៦	០	២៥	៧	៦៨
ការជួញដូរមនុស្ស	០	០	០	០	០
សរុប	**៥៦**	**១**	**៤៩**	**១៤**	**១២០**

ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប

ទិន្នន័យជនប្រប្រិត្តបទល្មើសដែលបានបញ្ជូនទៅកាន់ពន្ធធានាគា ឆ្នាំ២០២០

ករណី	**ភ.ព**	**ប.ជ**	**ស.រ**	**ក.ធ**	**សរុប**
អំពើហិង្សាក្នុងគ្រួសារ	៧	០	២	៤	១៣
រំលោភបំពានផ្លូវភេទ	៣៦	០	២៥	៧	៦៨
ការជួញដូរមនុស្ស	០	០	០	០	០
សរុប	**៤៣**	**០**	**២៧**	**១១**	**៨១**

ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប

២.៣ មណ្ឌលសុវត្ថិភាព

អតិថិជនដែលបានស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពរបស់អង្គការ CWCC ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និង ខេត្តបន្ទាយមានជ័យក្នុងឆ្នាំ២០២០ មានចំនួនសរុប១៣១នាក់ (ដែលក្នុងនោះមានជនរងគ្រោះ៨៩នាក់ និង សាច់ញាត្តិ៤២នាក់) ។ ក្នុងចំណោមពួកគេទាំងអស់ មានអតិថិជនអាយុក្រោម១៨ឆ្នាំ ចំនួន៨៧នាក់ (៦៣នាក់ជាជនរងគ្រោះ និង ២៤នាក់ជាសាច់ញាត្តិ)។ ក្នុងកំឡុងពេលនៃការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពជនរងគ្រោះ ទទួលបានការប្រឹក្សាជាបុគ្គល និងជាក្រុម ដើម្បីកសាងទំនុកចិត្ត និងភាពជឿជាក់លើខ្លួនឯង ។ អតិថិជនក៏ទទួលបានវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចជាជំនាញកាត់ដេរ ចំអិនម្ហូប ធ្វើនំ ជាត់មុខ ធ្វើសក់ និងថ្នាក់អក្ខរកម្មជាដើម ។ បន្ថែមពីនេះទៅទៀត អតិថិជនដែលមិនទាន់គ្រប់អាយុ បានបញ្ជូនអោយទៅសិក្សានៅសាលារដ្ឋដែលនៅជិតមណ្ឌល ហើយកុមារតូចៗដែលមានអាយុក្រោម៥ឆ្នាំទទួលបានសេវាថែទាំប្រចាំថ្ងៃ។

ចំនួនជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌល់សុវត្ថិភាពអង្គការCWCC ឆ្នាំ២០២០

	អាយុក្រោម ១៨ឆ្នាំ				**អាយុលើ ១៨ឆ្នាំ**				
ជនរងគ្រោះ	**ភ.ព**	**ប.ជ**	**ស.រ**	**សរុប**	**ភ.ព**	**ប.ជ**	**ស.រ**	**សរុប**	**សរុបរួម**
អំពើហិង្សាក្នុងគ្រួសារ	០	៤	៥	**៩**	៤	៤	១១	**១៩**	**២៨**
រំលោភបំពានផ្លូវភេទ	២១	១៣	១៤	**៤៨**	៤	០	០	**៤**	**៥២**

ការជួញដូរមនុស្ស	០	៦	០	**៦**	១	២	០	**៣**	**៩**
សរុប	**២១**	**២៣**	**១៩**	**៦៣**	**៩**	**៦**	**១១**	**២៦**	**៨៩**

សាច់ញាតិ	**អាយុក្រោម ១៨ឆ្នាំ**				**អាយុលើ ១៨ឆ្នាំ**				**សរុបរួម**
	ភ.ព	**ប.ជ**	**ស.រ**	**សរុប**	**ភ.ព**	**ប.ជ**	**ស.រ**	**សរុប**	
អំពើហិង្សាក្នុងគ្រួសារ	៥	៦	៣	**១៤**	០	០	៧	**៧**	**២១**
រំលោភបំពានផ្លូវភេទ	៨	១	០	**៩**	៩	២	០	**១១**	**២០**
ការជួញដូរមនុស្ស	០	១	០	**១**	០	០	០	**០**	**១**
សរុប	**១៣**	**៨**	**៣**	**២៤**	**៩**	**២**	**៧**	**១៨**	**៤២**
សរុបរួម	**៣៤**	**៣១**	**២២**	**៨៧**	**១៨**	**៨**	**១៨**	**៤៤**	**១៣១**

ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប

២.៤ គម្រោងសមាហរណកម្ម

ក្នុងឆ្នាំ២០២០ បន្ទាប់ពីករណីរបស់ជនរងគ្រោះត្រូវបានបញ្ចប់នៅតុលាការ មានជនរងគ្រោះចំនួន៨៥នាក់និងសាច់ញាតិចំនួន៥០នាក់ ត្រូវបានធ្វើសមាហរណកម្មទៅតាមសហគមន៍ដែលពួកគេជ្រើសរើស។ ក្នុងចំណោមជនរងគ្រោះទាំងអស់ មានជនរងគ្រោះចំនួន២៦នាក់ ទទួលបានជំនួយឧបត្ថម្ភគាំទ្រជាថវិការ និងសម្ភារៈសម្រាប់ការរស់នៅ ហើយមានជនរងគ្រោះចំនួន៧នាក់ទទួលបានជំនួយឧបត្ថម្ភគាំទ្រការធ្វើអាជីវកម្ម ដើម្បីធានាអោយបានការរស់នៅប្រកបដោយឯករាជ្យ និងនិរន្តរភាព ហើយចៀសផុតពីអំពើហិង្សា និងបរិយាកាសងាយរងគ្រោះណាមួយ ។ បុគ្គលិកគម្រោងនៅតែបន្តរ តាមដានស្ថានភាពរបស់អតិថិជនដែលបានធ្វើសមាហរណកម្ម តាមរយៈការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរក្នុងតំបន់ ការសួរសុខទុក្ខនៅផ្ទះអតិថិជន ដើម្បីធ្វើអោយប្រាកដំបាននូវការធ្វើសមាហរណកម្មមានភាពជោគជ័យ ។

ចំនួនអតិថិជនដែលបានធ្វើសមាហរណកម្ម ឆ្នាំ២០២០

ករណី	ជនរងគ្រោះ					សាច់ញាតិ					**សរុបរួម**
	ភ.ព	**ប.ជ**	**ស.រ**	**ក.ធ**	**សរុប**	**ភ.ព**	**ប.ជ**	**ស.រ**	**ក.ធ**	**សរុប**	
អំពើហិង្សាក្នុងគ្រួសារ	២	៦	១៦	៩	**៣៣**	០	៤	១៩	៩	**៣២**	**៦៥**
រំលោភបំពានផ្លូវភេទ	១៥	១២	១៦	៦	**៤៩**	០	០	១០	៨	**១៨**	**៦៧**
ការជួញដូរមនុស្ស	១	២	០	០	**៣**	០	០	០	០	**០**	**៣**
សរុប	**១៨**	**២០**	**៣២**	**១៥**	**៨៥**	**០**	**៤**	**២៩**	**១៧**	**៥០**	**១៣៥**

ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប

៣. កម្មវិធីតស៊ូមតិ

៣.១ ការសហការណ៍ជាមួយរាជរដ្ឋាភិបាល

នាយិកាប្រតិបត្តិអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមក្នុងកិច្ចប្រជុំសម្រាប់រៀបចំ Coordinated Mekong Ministerial Initiative Against Trafficking (COMMIT) Senior Officials Meeting លើកទី១៤ ដែលដឹកនាំដោយក្រសួងកិច្ចការ នារីនៅថ្ងៃទី០៩ ខែធ្នូ២០២០។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ។ កិច្ចប្រជុំបានពិភាក្សាលើបញ្ហាសំខាន់ៗពាក់ព័ន្ធនឹង SOM និងធ្វើបទបង្ហាញសាកល្បងរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល។ បន្ទាប់ពិកិច្ចប្រជុំនេះ កិច្ចប្រជុំលើកទី១៤ នៃ COMMIT SOM បានប្រព្រឹត្តិទៅនៅថ្ងៃទី ១៥ និង១៦ខែធ្នូ ២០២០ តាមរយៈប្រព័ន្ធអនឡាយ។ កិច្ចប្រជុំនេះដឹកនាំដោយប្រទេសវៀតណាម ដោយមានអ្នកចូលរួមពីប្រទេសកម្ពុជា ចិន ឡាវ មីយ៉ាម៉ា និងថៃ។ ប្រធានបទនៃកិច្ចប្រជុំផ្តោតលើ វិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ នៅប្រទេសកម្ពុជាកិច្ចប្រជុំ នេះបានរៀបចំឡើងនិងតំណាងដោយក្រសួងកិច្ចការនារីជាមួយអ្នកចូលរួម ៣៧នាក់ (១៣ស្ត្រី) ដែលៗនាក់មកពីសង្គមស៊ីវិល និងអង្គការអន្តរជាតិរតន:បានធ្វើបទបង្ហាញជំនួសឱ្យសង្គមស៊ីវិល។ ក្រៅពីនេះលោកស្រីនាយិកា ក៏បានចូលរួមកិច្ចប្រជុំផ្សេងដែលរៀបចំឡើងដោយក្រសួងពាក់ព័ន្ធ ដើម្បីផ្តល់ជាធាតុចូលដល់ការកសាងផែនការថ្នាក់ជាតិ និងគោលនយោបាយផ្សេងៗ ដូចជាផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩ ដល់ ២០២៣។

៣.២ យុទ្ធនាការស្វែងរកមតិគាំទ្រ

ដើម្បីជម្រុញដល់អ្នកផ្តល់សេវាក៏ដូចជាអ្នកអនុវត្តគោលនយោបាយ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានរៀបចំកម្មវិធីវិទ្យុចំនួន១០វគ្គ ដែលមានឈ្មោះថា "សម្លេងស្ត្រីសម្រាប់ការផ្លាស់ប្តូរ" ក្រោមពាក្យស្លោក "មិនមានស្ត្រីណាម្នាក់ត្រូវបានបោះបង់ចោលនោះទេ" ក្នុងមួយវគ្គៗមានវាគ្មិនចំនួន២នាក់ ។ កម្មវិធីវិទ្យុនេះត្រូវបានចាក់ផ្សាយតាមរកលធាតុអាកាសវិទ្យុ FM 102 និងតាមការផ្សាយផ្ទាល់តាមគេហទំព័រហ្វេសបុករបស់វិទ្យុផងដែរ ។ វាគ្មិនកិតិយសដែលចូលរួមក្នុងកម្មវិធីវិទ្យុនោះសុទ្ធសឹងតែជាមនុស្សសំខាន់មកពីក្រសួងនិងមន្ទីរខេត្តពាក់ព័ន្ធនានា ដែលមានដូចជាក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច ។ ក្នុងនោះផងដែរក៏មានវាគ្មិនកិតិយសមកពីអង្គការសង្គមស៊ីវិល ដូចជា អង្គការជនពិការកម្ពុជា អង្គការមនុស្សចាស់កម្ពុជា អង្គការពន្លឺពិភពលោក និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្ត ។ ក្រុមស្ត្រីគោលដៅក៏ត្រូវបានអញ្ជើញអោយចូលរួមជាវាគ្មិនកិតិយសក្នុងកម្មវិធីវិទ្យុនេះផងដែរ ។ ប្រធានបទនៃកិច្ចពិភាក្សាគឺទាក់ទងនឹងគោលនយោ

បាយដែលពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងស្ត្រី ជនពិការ មនុស្សចាស់ និងប្រជាជនចំណាកស្រុក ។ វាគ្មិនកិតិយសដែលមកពីស្ថាប័នក្រសួងបានបង្ហាញអំពីគោលនយោបាយ ដែលដោះស្រាយភាពងាយរងគ្រោះរបស់ស្ត្រី ដោយឡែកវាគ្មិនកិត្តិយសមកពីអង្គការសង្គមស៊ីវិលក្រៅរដ្ឋាភិបាលបានធ្វើការពិភាក្សាអំពីកម្មវិធីរបស់ពួកគេដែលជួយសម្រួលដល់ស្ត្រីងាយរងគ្រោះអោយទទួលបានសេវា ។ក្រុមគោលដៅបានលើកយកបញ្ហាពាក់ព័ន្ធទៅនឹងភាពងាយរងគ្រោះ និងតម្រូវការរបស់ពួកគេ រួមមានទាំងអនុសាសន៍សម្រាប់អ្នកផ្តល់សេវាគួអនុវត្តន៍ ដើម្បីជួយពួកគេ ។

ក្រៅពីការបង្ហាញនូវទស្សនៈរបស់វាគ្មិនកិតិយស ក៏មានផងដែរនូវការបញ្ចេញមតិយោបល់ចូលរួមពីអ្នកស្តាប់ និងមតិយោបលពីអ្នកដែលបានទស្សនាការផ្សាយផ្ទាល់តាមបណ្តាញហ្វេសបុក ។ កម្មវិធីវិទ្យុនេះបានជួយផ្តល់ពត៌មានសម្រាប់ក្រុមគោលដៅ និងសាធារណជនទូទៅអំពីគោលនយោបាយដែលដោះស្រាយបញ្ហារបស់ស្ត្រី ។ ស្របពេលជាមួយគ្នានេះផងដែរ កម្មវិធីនេះក៏បានជួយពង្រឹងអំណាចក្រុមស្ត្រីគោលដៅអោយបញ្ចេញមតិពិភាក្សាទៅកាន់សាធារណជន ទោះបីជាមានស្ត្រីមួយចំនួនមានភាពខ្មាស់អៀននៅពេលចាប់ផ្តើមនិយាយដំបូងក៏ដោយ ។

៤. កម្មវិធីអភិវឌ្ឍន៍អង្គការ

៤.១ នាយកក្រុមប្រឹក្សាភិបាល

នាយកក្រុមប្រឹក្សាភិបាលនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានប្រាំនាក់ដែលជាអ្នកដឹកនាំក្រុមអង្គការសិទ្ធិមនុស្សដ៏លេចធ្លោនៅកម្ពុជា៖ (១) ប្រធានក្រុមក្រុមប្រឹក្សាភិបាល លោកស្ត្រី គៀន សិរីផល ជាអ្នកបង្កើត និងជាអតីតប្រធានអង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជាCWDA) និងបច្ចុប្បន្ន លោកស្រីជាអ្នកប្រឹក្សាឯករាជ, (២) លោកមេធាវី សុក សំអឿន ជានាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលជាអង្គការជំនួយផ្នែកច្បាប់ដ៏លេចធ្លោនៅក្នុងប្រទេសកម្ពុជា, (៣) លោកស្រី រស់ សុភាព ជានាយិការប្រតិបត្តិ នៃអង្គការយេនឌ័រនិងការអភិវឌ្ឍនៅកម្ពុជា(GAD-C) ដែលជាអង្គការនាំមុខគេមួយ ធ្វើការដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ។ (៤) លោក ជា ពីដែន គឺជានាយកប្រតិបត្តិអង្គការគាំពារកុមារងាយទទួលរងគ្រោះ(VCAO) ដែលធ្វើការការពារសិទ្ធកុមារ និងលើកកម្ពស់ការចូលរួមរបស់កុមារ, និងជាចុងក្រោយ (៥) លោកស្រី ប៉ែន មនោរម្យ ដែលបច្ចុប្បន្នជានាយិការងអង្គការ PSI ។

៤.២ បុគ្គលិករបស់អង្គការ

ក្នុងឆ្នាំ២០២០ បុគ្គលិកអង្គការ CWCC មានបបុគ្គលិកសរុបចំនួន៦០នាក់ (បុរស២១នាក់)។ បុគ្គលិកដែលនៅការិយាល័យកណ្តាលមាន៩នាក់ (ស្រី៥នាក់) ការិយាល័យភ្នំពេញ ១៦នាក់ (ស្រី១១នាក់) ការិយល័យខេត្តសៀមរាបមាន១៧នាក់ (ស្រី១២នាក់) ការិយាល័យខេត្តបន្ទាយមានជ័យមាន ១០នាក់ (ស្រី៦នាក់) ការិយាល័យខេត្តកំពង់ធំមាន៨នាក់ (ស្រី៥នាក់)។

៤.៣ ការកសាងសមត្ថភាពបុគ្គលិក

បុគ្គលិកអង្គការCWCC បានទទួលការបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាពការងារ និងអភិវឌ្ឍបុគ្គលិក្នុំ២០២០ មានដូចជា៖

១. វគ្គបណ្តុះបណ្តាលអំពី "ការសង្គ្រោះផ្លូវចិត្តបឋមនិងការបង្ការ និងការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងយេនឌ័រ" រៀបចំដោយអង្គការ TPO នៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ដល់២៥ ខែវិច្ឆិកា ឆ្នាំ២០២០។

២. វគ្គបណ្តុះបណ្តាលអំពី "មូលដ្ឋានគ្រឹះនៃជំនាញពិគ្រោះយោបល់តាមទូរស័ព្ទ" រៀបចំដោយអង្គការ Spotlight Initiative ឧបត្ថម្ភដោយ EU និង United Nation កាលពីខែកក្កដា ឆ្នាំ២០២០។

Organization Structure



របាយការណ៍ហិរញ្ញវត្ថុ

ថវិការហិរញ្ញវត្ថុ ២០២០

ម្ចាស់ជំនួយ	មូលនិធិ	ភាគរយ
Lotus Outreach	115,348	16.30%
Georg Kraus foundation	10,907	1.54%
AOP	67,920	9.60%
Terre Des Hommes-Germany (TDH-G)	23,091	3.26%
ACCESS	120,092	16.97%
OXF-Voice	59,638	8.43%
FWC	6,980	0.99%
EU-Migra -Action	12,068	1.70%
FCA	102,746	14.52%
ILO	25,500	3.60%
SOLIDAR	78,187	11.05%
ATIKHA	16,785	2.37%
J-A-Clark	50,599	7.15%
ISSARA	13,490	1.91%
Earth Tree/MNN/Research	4,478	0.63%
សរុប	707,828	100%

ការចំណាយហិរញ្ញវត្ថុ ២០២០



ទំនាក់ទំនង៖

ការិយាល័យកណ្តាល

- អាសយដ្ឋាន៖ #១៣C ផ្លូវ៣៣១ បឹងកក២ ទួលគោក ភ្នំពេញ កម្ពុជា
- អាសយដ្ឋានប្រៃសណីយ៍៖ PO Box ២៤២១
- ទូរស័ព្ទ៖ (៨៥៥-២៣) ៩៩៧៩៦៧
- ទូរសារ៖ (៨៥៥-២៣) ៩៨៧១៥៨
- អ៊ីម៉ែល៖ HOadmin@cwcc.org.kh
- វេបសាយ៖ www.cwcc.org.kh

ការិយាល័យរាជធានីភ្នំពេញ

- អាសយដ្ឋាន៖ #៥២F ផ្លូវ៤៨៨ ផ្សារដើមផ្លូវ ចំការមន ភ្នំពេញ កម្ពុជា
- អាសយដ្ឋានប្រៃសណីយ៍៖ P.O Box ២៤២១ និង CCC box ៣៥៦
- ទូរស័ព្ទ៖ (៨៥៥-២៣) ៩៨៧១៥៨
- ទូរសារ៖ (៨៥៥-២៣) ៩៨៧១៥៨
- អ៊ីម៉ែល៖ PNPadmin@cwcc.org.kh PNPmanager@cwcc.org.kh

ការិយាល័យខេត្តបន្ទាយមានជ័យ

- អាសយដ្ឋាន៖ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត
- ទូរស័ព្ទ/ទូរសារ៖ (៨៥៥-៥៤) ៩៦៧ ១៤៤
- អីម៉ែល៖ BMCadmin@cwcc.org.kh BMCmanager@cwcc.org.kh

ការិយាល័យខេត្តសៀមរាប

- អាសយដ្ឋាន៖ ភូមិស្វាយដង្គុំ សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប
- ទូរស័ព្ទ/ទូរសារ៖ (៨៥៥-៦៣) ៩៦៣២៧៦
- អីម៉ែល៖ SRPadmin@cwcc.org.kh SRPmanager@cwcc.org.kh

ការិយាល័យខេត្តកំពង់ធំ

- អាសយដ្ឋាន៖ ផ្លូវលេខ ៨ ភូមិដំរីជាន់ខ្លា សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
- ទូរស័ព្ទ/ទូរសារ៖ (៨៥៥-៦២) ២១០៥១៥
- អីម៉ែល៖ KPTadmin@cwcc.org.kh KPTmanager@cwcc.org.kh

សូមថ្លែងអំណរគុណជំពោះម្ចាស់ជំនួយដូចខាងក្រោម៖